**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពី
## ចំណាត់ការលើអ្នកគ្រប់គ្រងជាជនបរទេសដែលប្រើប្រាស់អាកប្បកិរិយា និងពាក្យសម្តីមិនសមរម្យ ជាមួយបងប្អូនកម្មករនិយោជិតខ្មែរ

ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជម្រាបជូនដល់សាធារណជន សមាគមនិយោជក ម្ចាស់សហគ្រាស ក្រុមហ៊ុន រោងចក្រ និងបងប្អូនកម្មករនិយោជិត មេត្តាជ្រាបថា នៅថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២៦ បន្ទាប់ពីទទួលបានបណ្តឹងរបស់បងប្អូនកម្មករនិយោជិត និងបានពិនិត្យវិភាគយ៉ាងល្អិតល្អន់ទៅលើរូបភាព និងសំឡេងពីកាមេរ៉ាសុវត្ថិភាព ស្តាប់ការបំភ្លឺរបស់សាក្សី និងការសារភាពរបស់សាមីជន ក្រសួងបានតម្រូវឱ្យអ្នកគ្រប់គ្រងជាជនបរទេស ចំនួន ២រូប ក្នុងនោះ១រូប នៅរោងចក្រ ចាស៊ីន អេលេន (ខេមបូឌា) ហ្គាមេន មែនញូហ្វែកធើរីង ឯ.ក ស្ថិតនៅខេត្តកណ្តាល និង១រូបទៀត នៅរោងចក្រ មីង យ៉ាង អ៊ិនដាស្ទ្រី (ខេមបូឌា) ឯ.ក ស្ថិតនៅខេត្តកំពង់ស្ពឺ ដែលបានប្រព្រឹត្តអាកប្បកិរិយាមិនសមរម្យចំពោះបងប្អូនកម្មករនិយោជិត ធ្វើការសុំទោសជាសាធារណៈនៅចំពោះមុខបងប្អូនកម្មករនិយោជិត និងធ្វើកិច្ចសន្យាថាឈប់ប្រើប្រាស់អាកប្បកិរិយា និងពាក្យសម្តីមិនសមរម្យដែលប៉ះពាល់ដល់សេចក្តីថ្លៃថ្នូរ របស់បងប្អូនកម្មករនិយោជិតខ្មែរតទៅទៀត។ ប្រសិនជាមានករណីបែបនេះជាលើកទី២ នាពេលខាងមុខ ជនបរទេសនោះនឹងប្រឈមការដកហូតបណ្ណការងារជនបរទេស និងបណ្តេញចេញពីព្រះរាជាណាចក្រកម្ពុជា។

ឆ្លៀតក្នុងឱកាសនេះ ក្រសួងសូមរំលឹកសារជាថ្មីដល់អ្នកគ្រប់គ្រង មេការ និងអ្នកបកប្រែ នៃសហគ្រាស ក្រុមហ៊ុន រោងចក្រ ជាពិសេសជនបរទេស ត្រូវគោរពឱ្យបាននូវសុជីវធម៌ វប្បធម៌ ប្រពៃណីទំនៀមទម្លាប់របស់ខ្មែរ និងចៀសវាងជាដាច់ខាតការប្រើប្រាស់អាកប្បកិរិយា និងពាក្យសម្តីមិនសមរម្យនៅកន្លែងការងារ។ ក្នុងករណីរកឃើញ ឬទទួលបានពាក្យបណ្តឹងអំពីការប្រើប្រាស់អាកប្បកិរិយា និងពាក្យសម្តីមិនសមរម្យនោះ ក្រសួងនឹងចាត់វិធានការតាមច្បាប់ជាធរមាន។

បងប្អូនកម្មករនិយោជិតដែលបានឃើញ ឬរងនូវអំពើនានាក៏អាចជូនដំណឹងពីការប្រើប្រាស់អាកប្បកិរិយា និងពាក្យសម្តីមិនសមរម្យ ឬការមិនអនុវត្តលក្ខខណ្ឌការងារបានត្រឹមត្រូវនៅកន្លែងការងារ មកអធិការការងារ តាមរយៈប្រអប់បណ្តឹងអនាមិករបស់ក្រសួង (https://feedback.mlvt.gov.kh/feedback) ឬប្រព័ន្ធ Hotline លេខ «១២៨៦»។

អាស្រ័យហេតុនេះ សូមសាធារណជន សមាគមនិយោជក ម្ចាស់សហគ្រាស ក្រុមហ៊ុន រោងចក្រ និងបងប្អូនកម្មករនិយោជិត មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃ ៧រ៉ោច ខែស្រាពណ៍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០
រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២៦

ប្រអប់បណ្តឹងអនាមិក